# ត្រៀមខ្លួនយកជោគជ័យពីអងសន្និសិទ

## មុនអងសន្និសិទ

- សាកសួរកូនរបស់អ្នក ឲ្យគេប្រាប់សំណួរ និងសេចក្ដីខ្វល់ខ្វាយនានារបស់គេអំពីសាលារៀន ។
- ពិនិត្យមើលរបាយការណ៍ស្ដីពីការលូតលាស់, បណ្ណរបាយការណ៍ស្ដីពីចំណាត់ថ្នាក់, នឹងកិច្ចការសាលាដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ ។
- សរសេរជាបញ្ជីសំណួរផ្សេងៗ ដែលអ្នកចង់សាកសួរដល់គ្រូ ។ ចូរចាប់ផ្ដើមពីទម្រង់នៅក្នុងកូនសៀវភៅស្ដើងនេះ រួចហើយចុះបន្ថែមតៗទៅទៀត ។ ចូរយកបញ្ជីសំណួររបស់អ្នកទៅប្រជុំជាមួយអ្នកផង ។
- សរសេរប្រាប់ព័ត៌មានអំពីកូនរបស់អ្នក ដែលអ្នកយល់ថាគ្រូរបស់គេគួរតែដឹង ដូចជាមរណភាពរបស់គ្រួសារ, ការលែងលះប្ដីប្រពន្ធ, ការផ្លាស់ប្ដូរចំណូលប្រាក់កាស, ជម្ងឺរោគា, ឬការរើចូលទៅនៅផ្ទះថ្មីជាដើម ។
- បើអ្នកត្រូវការយានជំនិះ, ឈ្នួលមើលកូន, ឬត្រូវការផ្លាស់ប្ដូរម៉ោងឬថ្ងៃប្រជុំសន្និសិទ, សាលារៀនអាចជួយអ្នកបាន ។ ចូរទូរស័ព្ទទៅការិយាល័យសាលា រៀន ហើយសុំឲ្យគេជួយអ្នក ។
- បើអង់គ្លេសមិនមែនជាភាសាទីមួយរបស់អ្នកទេ, ចូររកនរណាម្នាក់ឲ្យជួយទាក់ទងទៅសាលារៀន ឲ្យបានមុនការប្រជុំអងសន្និសិទមាតាបិតា-គ្រូ ហើយស្នើ សុំឲ្យគេជួយផ្ដល់អ្នកបកប្រែភាសាណាម្នាក់ ដើម្បីជួយអ្នកក្នុងពេលប្រជុំ ។

## ក្នុងអងសន្និសិទ

- សូមអនុញ្ញាតឲ្យគ្រូចាប់ផ្ដើមបើកអងប្រជុំ ប៉ុន្តែធ្វើយ៉ាងណាកុំភ្លេចសួរសំណួរដែលនៅក្នុងបញ្ជីរបស់អ្នកមុនដែលពេលវេលាត្រូវផុតទៅ ។
- សូមសាកសួរគ្រូអំពីអ្វី ដែលកូនរបស់អ្នកគួរតែដឹង ហើយអាចធ្វើបាននៅដំណាច់ឆ្នាំសិក្សា ។ ចូររៀបចំផែនការមួយសំរាប់យុទ្ធវិធី ដែលអ្នកហើយនិងគ្រូ អាចនឹងធ្វើរួមជាមួយគ្នានឹងកូនរបស់អ្នក ដើម្បីឈោងចាប់គោលដៅទាំងឡាយនោះ ។
- គួររកមធ្យោបាយល្អ (ដូចជាការសរសេរលិខិត, ការហៅទូរស័ព្ទ, ការផ្ញើអ៊ីមែល) និងពេលវេលាសមរម្យ ដើម្បីទាក់ទងជាមួយគ្រូជាប់ជាប្រចាំក្នុងឆ្នាំសិក្សា ។

# បន្តការសន្ទនាពេញក្នុងមួយឆ្នាំ

## ក្រោយអងសន្និសិទ

- និយាយជាមួយកូនរបស់អ្នកអំពីអ្វីៗ ដែលគ្រូបានប្រាប់អ្នក, ជាពិសេសសេចក្ដីពោលសរសើរល្អៗ ។ និយាយពិភាក្សាអំពីគោលដៅនៃការរៀនសូត្រ ហើយ បង្កើតជាផែនការណាមួយឡើង ដើម្បីឈោងចាប់គោលដៅទាំងឡាយនោះជាមួយគ្នា ។
- ពិនិត្យសាឡើងវិញលើផែនការ ដែលអ្នកបានធ្វើជាមួយកូនរបស់អ្នកនិងគ្រូឲ្យបានរៀងរាល់ពីរបីអាទិត្យម្ដង ។
- ពិនិត្យមើលការប្ញបសិក្សារបស់កូនអ្នករៀងរាល់ថ្ងៃសំរាប់រកមើលសម្ភារសិក្សាផ្សេងៗ ដែលគេបានផ្ញើចេញពីសាលារៀនមក ។ ចូរអានមើលសម្ភារទាំង អស់ ។ បើអង់គ្លេសមិនមែនជាភាសាទីមួយរបស់អ្នកទេ, សូមសុំសាច់ញាតិ ឬមិត្តភក្ដិឲ្យជួយអានព័ត៌មាន ដែលសាលារៀនបានផ្ញើទៅឲ្យអ្នក ជាភាសាជាតិ របស់អ្នក ។
- ទាក់ទងទៅគ្រូរៀងរាល់វេលាណាដែលអ្នកមានចម្ងល់ ។ បើកូនរបស់អ្នករៀនសូត្រមិនសូវបានល្អ, គួររៀបចំឲ្យមានវិធីតាមដានការចូលរៀនជាប្រក្រតី ណាមួយជាមួយគ្រូ ដើម្បីអង្កេតមើលការរីកចំរើនរបស់កូន ។ បើអង់គ្លេសមិនមែនជាភាសាទីមួយរបស់អ្នកទេ, ចូររកមិត្តភក្ដិឲ្យជួយអ្នកទាក់ទងទៅគ្រូ ឬសុំទៅការិយាល័យសាលារៀន ឲ្យគេជួយរកអ្នកបកប្រែភាសាណាម្នាក់ ។
- គួរផ្ញើលិខិតថ្លែងអំណរគុណជូនដល់គ្រូ នៅពេលណាមានរឿងហេតុល្អៗកើតឡើងនៅក្នុងថ្នាក់រៀន ។
- សូមធ្វើយ៉ាងណាឲ្យប្រាកដថា កូនរបស់អ្នកយល់ដឹងថាសាលារៀនសំខាន់ណាស់សំរាប់ជីវិតគេ ។ សូមនិយាយជាមួយកូនរបស់អ្នកអំពីសាលារៀនឲ្យបាន រាល់ៗថ្ងៃ, គួរចូលរួមក្នុងព្រឹត្តិការណ៍នានាដែលសាលារៀនធ្វើ, ជួយតាមលទ្ធភាពដែលអាចធ្វើបានពីផ្ទះ, ស្ម័គ្រចិត្តជួយក្នុងថ្នាក់រៀន, ចូលរួមជាមួយអងការ មាតាបិតា ។


**Office of the Education Ombuds**
**(ការិយាល័យអាជ្ញាចាត់តាំងការស៊ើបអង្កេតបណ្ដឹងផ្នែកការសិក្សាអប់រំ)**

155 NE 100th St.
Ste. 210
Seattle, WA 98125-8012

**ទូរស័ព្ទឥតគិតថ្លៃ ៖ 1-866-297-2597**
**ទូរសារ ៖ 206-729-3251**
**www.oeo.wa.gov**


**(Office of the Education Ombuds) សូមទាក់ទងការិយាល័យអាជ្ញាចាត់តាំងការស៊ើបអង្កេតបណ្ដឹងផ្នែកការសិក្សាអប់រំ ប្រសិនបើអ្នកចង់ទទួលឯកសារនេះតាមទ្រង់ទ្រាយណាមួយផ្សេងទៀត ដើម្បីជួយសម្រួលដល់ជនពិការ ។**

(Office of the Education Ombuds) ការិយាល័យអាជ្ញាចាត់តាំងការស៊ើបអង្កេតបណ្ដឹងផ្នែកការសិក្សាអប់រំនឹ ងផ្ដល់ព័ត៌មាន ហើយនិងសេវាកម្មផ្នែកបញ្ជូនការបំរើ ជូនដល់ពួកសិស្ស, ដល់ក្រុម គ្រួសារ និងសហគមន៍នានាស្ដីពីប្រព័ន្ធសិក្សាអប់រំសាធារណៈ, លើកកម្ពស់ការចូលរួមរបស់គ្រួសារ និងសហគមន៍ក្នុងការសិក្សាអប់រំ, ព្រម ទាំងជួយក្រុម គ្រួសារ និងបណ្ដាពួកសិស្សក្នុងការស្វែរកការដោះស្រាយទំនាស់ជាមួយលាសារៀននានា ។



# ទាញយកអត្ថប្រយោជន៍ឲ្យបានច្រើនពីអងសន្និសិទមាតាបិតា-គ្រូ
# Make the Most of Parent-Teacher Conferences

ការិយាល័យអាជ្ញាចាត់តាំងការស៊ើបអង្កេតបណ្ដឹងផ្នែកការសិក្សាអប់រំ
Office of the Education Ombuds

**ក្បួនណែនាំសំរាប់គ្រួសាររបស់សិស្សសាលាបឋមសិក្សា**
**A Guide for Families of Elementary School Students**

Washington State Governor's Office of the Education Ombuds
We listen. We inform. We help solve problems.

រដ្ឋវ៉ាស៊ីនតោន
ការិយល័យអភិបាលរដ្ឋ
State of Washington
Office of the Governor

**Cambodian**

# ទៅរួមប្រជុំក្នុងអង្គសន្និសិទ មាតាបិតា-គ្រូ

សាលារៀនភាគច្រើនបានអញ្ជើញរាល់គ្រួសារសិស្សទៅរួមប្រជុំក្នុងអង្គសន្និសិទមាតាបិតា-គ្រូក្នុងមួយឆ្នាំម្តង ។ សន្និសិទគឺជាវេលាមួយសំរាប់ឪពុកម្តាយ និងគ្រូចែករំលែកពត៌មាន, ដោះស្រាយបញ្ហា, និងកសាងទំនាក់ទំនង ដែលនឹងជួយសិស្សឲ្យបានជោគជ័យក្នុងការរៀនសូត្រ ។ តែអ្នកមិនត្រូវការរង់ចាំរហូតទាល់តែមានការអញ្ជើញពិសេសណាមួយទេ ។ អ្នកអាចស្នើសុំឲ្យគេបើកអង្គប្រជុំណាមួយជាមួយគ្រូរបស់កូនអ្នក ដើម្បីពិភាក្សាអំពីការរីកចំរើននៃការរៀនសូត្រនៅពេលណាក៏បានដែរ ។

គ្រូត្រូវការពួពីអ្នក ហើយអ្នកក៏ត្រូវការពួពីគ្រូ ។ អ្នកជាបុគ្គលតែម្នាក់ដែលសាល់កូនរបស់អ្នកច្បាស់ជាងគេឯងនៅឯសាលារៀន ។ ការនិយាយជាមួយគ្រូអំពីកូនរបស់អ្នកនឹងជួយបើកផ្លូវឲ្យសិស្សរបស់អ្នកអាចរៀនសូត្រពូកែនៅក្នុងថ្នាក់ ហើយក៏នឹងជួយអ្នកឲ្យអាចយល់ដឹងអំពីអ្វី ដែលគេកំពុងតែបង្ហាត់បង្រៀនសិស្ស នៅក្នុងថ្នាក់រៀនដែរ ។

សន្និសិទជាធម្មតាខ្លីទេ ហើយនិយាយចំៗចំណុចតែម្តង ។ គន្លឹះជំនួយទាំងនេះនឹងជួយអ្នកឲ្យទាញបានកម្រៃជាច្រើនពីពេលវេលា ដែលអ្នកចំណាយជាមួយគ្រូ របស់កូនអ្នក ។

# លិខិតកំណត់ហេតុនៃអង្គសន្និសិទ មាតាបិតា-គ្រូ

ដោចំណាំសំណួរនានា ដែលមានសារសំខាន់ចំពោះអ្នក, ហើយបន្ថែមសំណួរផ្សេងៗទៀត ។ យកទម្រង់នេះទៅជួបអង្គសន្និសិទរបស់អ្នក ។

## សំណួរនានាសំរាប់គ្រូ

- ☐ អ្នកអាចបង្ហាញឲ្យខ្ញុំមើលការងារខ្លះៗរបស់កូនខ្ញុំបានទេ?
- ☐ តើកូនខ្ញុំបានបញ្ចប់វិញ្ញាសានានាក្នុងថ្នាក់ហើយប្រគល់កិច្ចការសាលាដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះទៅឲ្យគ្រូវិញឬទេ?
- ☐ តើកូនខ្ញុំចូលរួមជាមួយក្រុមពិភាក្សាកិច្ចការរៀនសូត្រក្នុងថ្នាក់ឬទេ?
- ☐ តើអ្នកពេញចិត្តជាមួយការរីកចម្រើនរបស់កូនខ្ញុំឬទេ?
- ☐ តើកូនខ្ញុំពូកែធ្វើអ្វីខ្លះ? តើកូនខ្ញុំកំពុងមានបញ្ហាលំបាកជាមួយអ្វីខ្លះ?
- ☐ តើយើងអាចទៅរកជំនួយនៅទីណាបាន?
- ☐ តើកូនរបស់ខ្ញុំសម្តែងឥរិយាបថនៅក្នុងថ្នាក់រៀននិងនៅលើទីធ្លាលេងកំសាន្តយ៉ាងណាខ្លះ?
- ☐ ថ្មីៗនេះ តើមានការផ្លាស់ប្តូរអ្វីមួយ ដែលខ្ញុំគួរតែយល់ដឹងអំពីខ្លឹមសាររបស់វាឬទេ?
- ☐ តើអ្នកប្រកាន់របៀបដាក់វិន័យយ៉ាងណា?
- ☐ តើការរំពឹងចង់បានរបស់អ្នកពីកូនរបស់ខ្ញុំមានអ្វីខ្លះ?
- ☐ តើអ្នកនឹងចេញវិញ្ញាសាប្រឡងអ្វីខ្លះនៅឆ្នាំនេះ? តើកូនរបស់ខ្ញុំត្រូវការត្រៀមខ្លួនយ៉ាងណាខ្លះ?
- ☐ តើនឹងមានគម្រោងកម្មវិធីធំៗត្រូវចេញប្រើឬទេ? តើខ្ញុំអាចជួយកូនខ្ញុំរបៀបណា?
- ☐ តើអ្នកផ្ញើប័ណ្ណរបាយការណ៍ចំណាត់ថ្នាក់ចេញនៅពេលណា?
- ☐ តើការឲ្យពិន្ទុអាស្រ័យលើអ្វីខ្លះ?
- ☐ តើមានមធ្យោបាយល្អណាខ្លះសំរាប់ឲ្យយើងរក្សាការទាក់ទងគ្នាស្តីពីការរីកចំរើនរបស់កូនខ្ញុំក្នុងឆ្នាំនេះ?
- ☐ តើមានសិស្សប៉ុន្មាននាក់កំពុងរៀននៅក្នុងថ្នាក់នេះ?
- ☐ តើអ្នកមានគ្រូជំនួយឬទេ? តើអ្នកប្រើឪពុកម្តាយស្ម័គ្រចិត្តឲ្យជួយនៅក្នុងថ្នាក់រៀនឬទេ?
- ☐ តើអ្នកមានអនុសាសន៍អ្វីសំរាប់ខ្ញុំ ដើម្បីចូលរួមជាមួយសាលារៀន ហើយនិងជួយកូនខ្ញុំឲ្យទទួលបានជោគជ័យឬទេ?
- ☐ តើខ្ញុំអាចសុំកាលវិភាគអង្គប្រជុំរបស់ឪពុកម្តាយ និងការប្រារព្ធពិធីបើកថ្នាក់ដំបូងៗក្នុងកំឡុងឆ្នាំសិក្សានេះបានទេ?
- ☐ តើគេបានឃើញវប្បធម៌របស់ខ្ញុំឆ្លុះបញ្ចាំងក្នុងពេលរៀនសូត្រក្នុងថ្នាក់យ៉ាងណាដែរ?

### ប្រលោះចំហសំរាប់ចុះកំណត់ហេតុ

## រឿងរ៉ាវនានាដែលត្រូវជំរាបប្រាប់គ្រូ

- ☐ របៀបដែលកូនខ្ញុំរៀនសូត្រពូកែបំផុត ។
- ☐ ការផ្លាស់ប្តូរធំៗណាមួយនៅក្នុងគ្រួសារ — ផ្ទះថ្មី, មនុស្សថ្មីៗមករស់នៅក្នុងផ្ទះ, មរណភាព, ឬការលែងលះប្តីប្រពន្ធ ។
- ☐ ស្ថានភាពវេជ្ជសាស្រ្តនានាដែលបង្កផលប៉ះពាល់ដល់កូនរបស់ខ្ញុំ ។
- ☐ អ្វីដែលធ្លាប់ជួយឲ្យកូនរបស់ខ្ញុំរៀនសូត្របានជោគជ័យក្នុងអតីតកាល ។
- ☐ អ្វីដែលធ្វើឲ្យកូនរបស់ខ្ញុំសប្បាយរីករាយអំពីសាលារៀន និងថ្នាក់រៀន ។
- ☐ អ្វីដែលកំពុងរារាំងយ៉ាងខ្លាំងក្លាបំផុតសំរាប់កូនខ្ញុំនៅក្នុងថ្នាក់នេះ ។

### ប្រលោះចំហសំរាប់ចុះកំណត់ហេតុ

### ការបន្តផែនការនានា ពត៌មានទាក់ទងរបស់គ្រូ

### រឿងរ៉ាវដែលត្រូវធ្វើ